**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

(ASPIRE)

# គោលការណ៍វេទិកាសាធារណៈថ្នាក់ស្រុក

# District Forum Guidelines

**រៀបចំដោយ :** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

**ឧបត្ថម្ភដោយ:** កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

IFAD

Investing in rural people

ភ្នំពេញ ខែ កុម្ភៈ ឆ្នាំ ២០១៧

Reference #.........................
Version: 001

# មាតិកា


សេចក្តីផ្តើម ........ 3
- ១ ពេលវេលា. ........ 3
- ២ ទីកន្លែង ........ 3
- ៣ ប្រធានបទវេទិកាសាធារណៈ. ........ 3
- ៤ អ្នកចូលរួម ........ 4
- ៥ គណៈអធិបតី ........ 4
- ៦ វាគ្មិន ........ 4
- ៧ អ្នករៀបចំ ........ 4
- ៨ អ្នកសម្របសម្រួល ........ 5
- ៩ ឯកសារជំនួយស្មារតី ........ 5

គំរូឯកសារជំនួយស្មារតី ........ 5
សេចក្តីផ្តើម ........ 5
- ១ គោលបំណង. ........ 5
- ២ លទ្ធផលរំពឹងទុក ........ 6
- ៣ អ្នកចូលរួម ........ 6
- ៤ វាគ្មិន ........ 7
- ៥ អ្នកសម្របសម្រួល ........ 7
- ៦ កម្មវិធី ........ 8


DRAFT

## សេចក្តីផ្តើម

យោងទៅតាមគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា វេទិកាសាធារណៈថ្នាក់ស្រុកគឺជាផ្នែកមួយសម្រាប់ ការធ្វើឲ្យប្រសើរនូវសេវាផ្សព្វផ្សាយដែលបានផ្តល់នៅថ្នាក់ស្រុក និងថ្នាក់ខេត្ត។ វេទិកាសាធារណៈ គឺត្រូវការសហការរវាងបណ្តាញ និងក្រុមគាំទ្របច្ចេកទេសកសិកម្មថ្នាក់ខេត្តមាន ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទជាអនុប្រធាន ក្រុមគាំទ្របច្ចេកទេសថ្នាក់ស្រុក ដែលមានអភិបាលស្រុកជាប្រធាន អង្គការក្រៅរដ្ឋាភិបាល មន្រ្តីការិយាល័យកសិកម្មស្រុក ភ្នាក់ងារផ្សព្វផ្សាយឃុំ អង្គការសហប្រជាជាតិ ផ្នែកជន សហគមន៍អភិវឌ្ឍន៍កសិកម្ម និងក្រុមកសិករ។

គោលការណ៍ណែនាំនេះមានគោលបំណងផ្តល់ការអប់រំ ថាតើត្រូវរៀបចំ និងដំណើរការវេទិការសាធារណៈថ្នាក់ស្រុកនៅថ្នាក់ស្រុកយ៉ាងដូចម្តេច។ ដូច្នេះហើយសម្រាប់អ្នកអនុវត្តត្រូវចាប់ផ្តើមវេទិការសាធារណៈមានប្រាំបួនជំហាន ដូចខាងក្រោមៈ

## ១.ពេលវេលា

វេទិការសាធារណៈគួរចាប់ផ្តើមរវាងខែ មេសា និងខែ កក្កដា ជារៀងរាល់ឆ្នាំ ដើម្បីផ្តល់ឱកាសសម្រាប់កសិករ ផ្នែកឯកជនលក់សម្ភារៈកសិកម្ម អ្នកប្រមូលទិញ អ្នកទិញ និងអ្នកពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីផលិតផល និងតម្រូវការទីផ្សារ។ ដូច្នេះពេលវេលាអាចត្រូវបានផ្លាស់ប្តូរ គឺប្រែប្រួលទៅតាមស្ថានភាពក្នុងស្រុកនីមួយៗ។

## ២.ទីកន្លែង

វេទិការសាធារណៈថ្នាក់ស្រុកគួរតែធ្វើឡើងនៅការិយាល័យកសិកម្មស្រុក ឬ សាលាស្រុក។

## ៣.ប្រធានបទវេទិការសាធារណៈ

វេទិការសាធារណៈថ្នាក់ស្រុកគួរតែពិភាក្សានូវប្រធានបទដូចខាងក្រោមនេះ:

- ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ ទៅលើកសិកម្ម ការប្រកបរបរចិញ្ចឹមជីវិត ហេដ្ឋារចនាសម្ព័ន្ធ និងតម្រូវការទីផ្សារ
- ឱកាស បញ្ហា និងដំណោះស្រាយ អំពីតម្រូវការទីផ្សារ អ្នកផ្គត់ផ្គង់ តម្លៃ គុណភាព បរិមាណនៃផលិតផល និងខ្នាតគម្រូនៃផលិតផលកសិកម្ម (GAP, CAMGAP ផលិតផលកសិកម្មសរីរាង្គ.........)
- កិច្ចសហប្រតិបត្តការរវាងតួអង្គផ្សេងៗក្នុងចង្វាក់ទីផ្សារ ឈ្មួញកណ្តាល កសិករ អ្នកទិញ អាជ្ញាធរ មន្រ្តីផ្សព្វផ្សាយ ភ្នាក់ងារផ្សព្វផ្សាយឃុំ និងផ្នែកឯកជនលក់សម្ភារៈកសិកម្ម។